
ឥន្ទធនូកណ្តាលភ្លៀង




គំនូរដោយ សៅ ស្រីម៉ៅ

និពន្ធដោយ អង្គការសហគមន៍ឥន្ទធនូកម្ពុជា

សំណេរដៃដោយ អាឡិច លីហ្វ



រក្សាសិទ្ធិគ្រប់យ៉ាងដោយ អង្គការសហគមន៍ឥន្ទធនូកម្ពុជា ឆ្នាំ ២០២០



ISBN :





សុភាព ចាកចេញពីស្រុកកំណើតខេត្តបាត់ដំបង ដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យក្រុងភ្នំពេញ ។ សុភាព គិតក្នុងចិត្តថា វាគឺជាជំហានដ៏ធំមួយ ក្នុងការរស់នៅដោយខ្លួនឯង ។
លាហើយបាត់ដំបង ទឹកដីកំណើតខ្ញុំអើយ! ម្តងនេះ ដំណើរខ្ញុំហាក់ដ៏វែងឆ្ងាយណាស់! ប៉ុន្តែមិនអីទេ វាក៏ជាឱកាសល្អមួយដែរ ដែលឲ្យខ្ញុំអាចរៀនរស់នៅដោយឯករាជ្យ និងពឹងលើខ្លួនឯង ។ បាត់ដំបងអើយ! សូមកុំភ្លេចខ្ញុំណា! ខ្ញុំមិនភ្លេចឯងទេ!
ចា៎! ខ្ញុំយកខោមួយនេះ!
ប្អូនចង់កាត់ម៉ូតអ្វីដែរ?
បង! សុំកាត់ឲ្យខ្លី សុំម៉ូតរាងស្ទាវបន្តិច តែបែបសុភាពណាបង ក្រែងគ្រូមិនឲ្យចូលថ្នាក់ ។


ឃី ! សមគ្រាន់បើ !
អស់តែ ៥០០០៛ ! តែប៉ុណ្ណោះ
បានសង្ហានឹងគេហើយ ។
ម៉េចដែរប្អូន ?
ប៉ុណ្ណឹងបានទេ ?
អើយ៉ាឡូយមែន !
បងកាត់ត្រូវចិត្តខ្ញុំម៉ង់តែម្តង ។
ខ្ញុំចូលចិត្តណាស់ ! អរគុណបង !


វូសៗ!!
វូស!!
ជ័នរាគី! អញហ្ន៎! ហ្អែងមើលអញមិនស្គាល់ ឬម៉េចហ្ន៎ បានជាព្រុសនេះ ព្រុស? ហ្អែង ចូលចិត្តម៉ូតសក់ថ្មីអញអត់ហ្ន៎?
ថ្ងៃបន្ទាប់...
ថ្ងៃនេះ ធ្វើខ្លួនឲ្យ សង្ហា ទៅសាលាមើល!


រូរឺរណោ ណោៗ ណោៗ...
សាកលវិទ្យាល័យ
ចម្លែកៗ! ខ្លួនជាស្រី ម៉េចបានជាតែងខ្លួនជាប្រុស ចឹងហ្ន៎! មិនចេះខ្មាសគេ!
យីស្រីនោះ គួរស្អប់តែប្រុស! ហើយត្រូវរស់ជាអីហ្នឹង?
ហឹ! ម៉េចក៏ស្លៀក ពាក់អីចឹងមិនបាន?
ពៅសុភាព! ស្លៀកខោអីចឹង មិនត្រូវទេណា ។ ខ្លួនជាស្រី ត្រូវស្លៀកសំពត់ដូចគេឯងដែរ ។ បើស្លៀកខោរបៀបហ្នឹង គ្រូមិន ឲ្យចូលរៀនជាដាច់ខាត ។


សុភាព!


សុភាព! យី! ហៅប៉ុណ្ណឹង ហើយ មិនឮទៀត!



សុំទោស!
ឯងឈ្មោះអី?
ខ្ញុំឈ្មោះជីតា! ខ្ញុំអង្គុយក្រោយឯងហ្នឹង តែប្រហែលឯងមិនឃើញខ្ញុំទេមើលទៅ!?!
អូ! សុំទោស! ខ្ញុំអត់ទាន់ស្គាល់គេអស់ផង ។ អរគុណដែលបានហៅ ។
ថ្ងៃបន្ទាប់...
មើលទៅសុភាព
ស្លូតដាមានស្ងៀមអី!


សុភាព ! កើតអីហ្នឹង ?
មើលទៅដូចជាអត់សប្បាយចិត្តចឹង ?
ហ៊ឺ ! តើខ្ញុំត្រូវធ្វើម៉េចទៅហ្ន៎ ?
ហ៊ឺ ! មើលទៅអត់មានអ្នកណាចូលចិត្តខ្ញុំសោះ សូម្បីតែគ្រូ ក៏មិនឲ្យខ្ញុំស្លៀកខោវែង ។
អត់អីទេ សុភាព ! ឥឡូវយើងសាកទៅពិគ្រោះជាមួយអ្នកគ្រូនាយិកាមើល ក្រែងគាត់ជួយសុភាពបាន ។
គក គក
ជំរាបសួរអ្នកគ្រូ !
ជំរាបសួរអ្នកគ្រូនាយិកា !


មានការរើសើរ រឿងតើរាក់ហ្នឹង?
អ្នកគ្រូ! ខ្ញុំកើតមកស្រីមែន តែខ្ញុំមានអារម្មណ៍ជាប្រុស ។ ខ្ញុំចង់កាត់សក់ និង ស្លៀកពាក់ជាប្រុស ។ ពេលគ្រូហាមរញ្ជឹន ខ្ញុំពិបាកក្នុងខ្លួនណាស់!
ចាំ! គ្រូថ្នាក់ពួកខ្ញុំមិនឲ្យសុភាព ស្លៀកឯកសណ្ឋានប្រុសទេ ព្រោះគាត់ថា សុភាពជាស្រី ។
ពុទ្ធោ! គាត់ហាមរញ្ជឹងដែរ? តាមពិតទៅ ការស្លៀកពាក់របៀបចំខ្លួនទៅតាមភេទសញ្ញាណយេនឌ័រ គឺជាការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ឲ្យតែសមរម្យជាសិស្សទៅបានហើយ ។


អឺណេ! កុំបារម្ភអី ចាំអ្នកគ្រូជួបប្រជុំជាមួយលោកគ្រូ អ្នកគ្រូទាំងអស់ ហើយពន្យល់ឲ្យគាត់យល់រឿងនេះណា៎ ។
មួយសប្តាហ៍ក្រោយមក...
អ្នកគ្រូ លោកគ្រូទាំងអស់គ្នា! ខ្ញុំបានលឺថាមាន គ្រូហាមសិស្សស្រីម្នាក់ មិនឲ្យស្លៀកខោចូលរៀន ត្រូវស្លៀកសំពត់ ។ ក្នុងនាមយើងជាគ្រឹះស្ថាន អប់រំ យើងត្រូវធ្វើយ៉ាងឲ្យសិស្សមានអារម្មណ៍ កក់ក្តៅ មានសុវត្ថិភាព និងទទួលបានចំណេះ ដឹងពេញលេញ ។ ការស្លៀកខោ ឬសំពត់ វាមិនគួរជាបញ្ហាទេ ។
ពីរសប្តាហ៍ក្រោយមក...
ប្អូនៗទាំងអស់គ្នា! នេះជាបទបញ្ជាផ្ទៃក្នុងថ្មី ដើម្បីធានាថា សិស្សគ្រប់រូបទទួលបានការអប់រំ និងការការពារស្មើៗគ្នា ។


សុភាព ! យើងដោះស្រាយបានហើយ ! ឥឡូវ មិនចាំបាច់បារម្ភទៀតទេ !
ធីតា ចិត្តល្អមែនហ្ន៎ !
អរគុណធីតា ! ខ្ញុំសប្បាយចិត្តណាស់ ! កុំតែបានធីតាជួយ កុំអីខ្ញុំច្បាស់ជាពិបាកមិនខាន ហើយក៏មិនបានសម្រេចការរៀនដែរ ។
តោះយើងទៅរកអ្វីញ៉ាំហ្ន៎ ?
តោះដើរ !


សុភាព ! ញញឹមមួយមើល !
តែសែលហ្វីមួយ !
ច្រិច !
សុំផុសមួយសិន !
Thida is with Sopheap


តើចង់ខ្ញុំលប់ស្រលាញ់គេណា?
គ្រាន់តែផុស ភ្លាម មានគេ like ភ្លាម! ហ៊ិហ៊ិ!
2♥
នៅផ្សារបាត់ដំបងវិញ...
ហ្អាក! នេះដូចជា កាភាព កូនងាងប្រែមតើ! ម៉េចក៏ខុសពីមុនខ្លាំងម្ល៉េះ?
នែងាងប្រែម! ម៉េចក៏កាភាពកូន ឯងនឹង តឡូវតុបតែងខ្លួនជាប្រុសចឹង? ហើយតែកៀកកើយជាមួយ មនុស្សស្រីទៀត!
ហ្អាស!!! ចាម៉េច?!
នុះ...កូនមីងឯង វីវរហើយ!
យី! កាភាព មែនតើ!
ម៉េចក៏កាភាព ទៅជា ដឹងរស់ទៅហ៊ុំ!?
សង្ស័យកើតភ្លើន តាមក្មេងក្រុងហើយ!
អញហ៊ើយ អញ!


ពុទ្ធោ! កាភាពាកូនអេញ ម៉ែចង់ទៅផ្សារហ្នឹង! អេញ ប្រេះទ្រូងដាច់ផ្លូវហើយ!
ព្រហ្ម ញ៉ើយ! ក្មេងៗ សម័យឥឡូវ វាស្រួលព្រងើយ តាមគ្នាហ្នឹង ។
ម៉ែ! ម៉ែអត់អីហ្សេម៉ែ?
ភ័ក្រ! កូនសុំជួយតេទៅ និយាយជាមួយ កាភាពាឲ្យ ម៉ែបន្តិចកូន!


ទីង តាវីង ទីង ៗ...
MOM
Calling...
អាឡូម៉ែ!
ពេលនោះ សុភ័ក្រប្រាប់សុភាពឲ្យឈប់តែងខ្លួនជាប្រុសទៀត ព្រោះវានាំឲ្យខូចកិត្តិយសគ្រួសារ ។
ម៉ែ ខ្ញុំប្រាប់មីអូនរួចហើយ ឈប់ពិបាកចិត្តទៅ ។
សុភាព! អ្នកណាគេ មកហ្នឹង បានធ្វើមុខ ដូចប្លូញចឹង?
ធីតា! ម៉ែ និងបងប្រុសខ្ញុំតេមក ។ គាត់ឃើញរូបមេរីងតាមហ្វេសប៊ុក ។ គាត់ប្រាប់កុំឲ្យខ្ញុំធ្វើខ្លួនអញ្ចឹងទៀត ។


ខ្ញុំខំពន្យល់គាត់ដែរ ថាខ្ញុំ អត់មានពេលនឹងទីក្រុង ឬធ្វើតាមគេទេ ។
តែពុកគាត់នៅតែ មិនយល់ពីខ្ញុំសោះ! ខ្ញុំគួរ ធ្វើម៉េចទៀតទៅ?
កុំទាន់បាក់ទឹកចិត្តណា ភាព ។ រឿងអីក៏ដោយ តែងតែមាន ដំណោះស្រាយ ដូចរឿងនៅសាលា ថ្ងៃមុនចឹង ។
ហ៊ឺ! ខ្ញុំបារម្ភថា អ្នកភូមិចំអក ឲ្យគាត់ ។ ទោះយ៉ាងណា ខ្ញុំមិនអាច តែងខ្លួនជាស្រីវិញទេ ព្រោះ អារម្មណ៍ខ្ញុំ ជាប្រុស ។


ស្អែកឡើង សុភាពក៏សម្រេចចិត្តទៅជួប ពិគ្រោះជាមួយលោកតា ដែលជាព្រះសង្ឃ ។
ករុណា ថ្វាយបង្គំ តេជគុណ
ខ្ញុំករុណា ខំនិយាយពន្យល់ម៉ែដែរ តែនិយាយម៉េច ក៏គាត់មិនព្រមស្ដាប់សោះ ។ លោកតាជួយករុណាផង ។
ធ្វើចិត្តឲ្យស្ងប់សិនញោម! ចាំអាត្មាសាកនិយាយម្ដងមើល ។
មួយសន្ទុះក្រោយ...
ញោម! មនុស្សម្នាក់ៗ មាន ឧបនិស្ស័យផ្សេងៗគ្នា ។ ចរិតមនុស្សក៏អញ្ចឹងដែរ ។ កើតមកជាស្រីមែន តែនិស្ស័យអាចជាប្រុស ។ សំខាន់វាជាកូនយើង ហើយប្រកបដោយកុសលធម៌ ។
លោកប្អូន! តែ កាភាពពីមុន វាមិនអញ្ចឹងទេ ។ តើឯវាត្រូវស្នេហ៍គេទៅ?
ម៉ែ! មើល ទៅលោកតាកាន់ជើង កាភាពហើយ ។ យើង រកវិធីផ្សេងវិញ ។


៣ ថ្ងៃក្រោយមក...
ម៉ែគ្រូ! ជួយមើលកូនស្រីខ្ញុំមើល! មានត្រូវស្នេហ៍គេអត់? វាទៅធ្វើខ្លួនជាប្រុស ហើយទៅតែក្លៀកកើយជាមួយស្រី ៗ សូមម៉ែគ្រូជួយផង!
អើ! មានរូបវាអត់? ហើយកើតឆ្នាំអើដែរ?
ភាំង
អើ កុំព្រួយអី! តែប៉ុណ្ណឹង មួយអាទិត្យទៀត វានឹងត្រលប់មកដូះវិញជាមិនខានទេ ៗ


ឃី! មួយអាទិត្យទៅហើយ ណៅមិនទាន់ឃើញកាភាពមកផ្ទះ វិញទៀត!
ភ័ក្រ កូន! ប្អូនឯង អត់ឃើញមកផ្ទះវិញ ដូចម៉ែគ្រូចាទេ!
ម៉ែ! ប្រហែលស្នេហ៍គេ ផ្ញើប្អូន ខ្លាំងពេកទេដឹង?


បាទម៉ែ!
ភ័ក្រ! មិនបានទេ ត្រូវតែទៅ កាភពាភ្លាម ហើយប្រាប់ចាន់ម៉ៃឈឿ ឲ្យវាសុំ ច្បាប់សាលាមកផ្ទះវិញភ្លាម ។
អាឡូ! មីមួន! ម៉ែឥឡូវឈឺធ្ងន់ហើយ ។ មីមួនឯងឆាប់មក ផ្ទះមក ។
MOM Calling...
ម្ដាយខ្ញុំឥឡូវឈឺធ្ងន់ណាស់ ។ ខ្ញុំត្រូវប្រញាប់ទៅស្រុកមើលគាត់ ។ ខ្ញុំបារម្ភសល់ហើយ ផឹតា ។
ភាព! កើតអី ទៀតហើយហ្នឹង?
ខ្ញុំសួនពរឲ្យមីមឆាប់ជាណា ភាព! ហើយកុំភ្លេចថែខ្លួនផង ។




ពុទ្ធោ! កូនស្រីមាសម្ដាយ! ម៉េចក្លាយជាបែបនេះកូន ?
តាមពិត ម៉ែអត់ឈឺផងហ្នឹង!
បើម៉ែមិនធ្វើអញ្ចឹង ស្មានតែកូនវិលមកផ្ទះហ្អី ?
ខ្ញុំអត់ត្រូវស្នេហ៍ណាគេទេ ។ តាមពិត ខ្ញុំមានអារម្មណ៍ជាប្រុសនេះយូរហើយ តែអត់ហ៊ានប្រាប់ម៉ែ ។
ម៉ែទៅមើលគ្រូហើយ ឃើញថាកូនឯងត្រូវស្នេហ៍គេ ។
ឃើស! តាមតែឲ្យប៉ប៉ះ! ស្ដាប់ម៉ែខ្លះមើល ។
មិនដឹងទេ ឈប់រៀន ហើយការយកប្ដីទៅ!
ហ៊ឺ! ធុញចប់ហ្អស់! ម៉េចក៏គ្មានអ្នកណាយល់ពីអ្នកជុំវិញខ្ញុំតាំងពីតូច
ខ្ញុំត្រូវធ្វើម៉េចទៅ ? ខ្ញុំជឺវិ ? សូម្បីតែម៉ែ ក៏នៅមិនយល់ពីខ្ញុំទៀត ។


ភាព! ឆាប់ដេកទៅកូន ។ ស្អែកព្រឹកម៉ែនាំទៅស្រោចទឹក ស្ដោះស្នេហ៍ដោះគ្រោះចេញ ។
ខ្ញុំអត់មានត្រូវស្នេហ៍ ត្រូវគ្រោះអីទេ ។ តាំងពីតូចមក ខ្ញុំមានអារម្មណ៍ចឹង ។ ម៉ែចង់ម៉ែដៅ តែមិនស្ដាប់ខ្ញុំ ។
ហ៊ឺ! កូនអញ! អាណិតវាណាស់ តែខ្ញុំត្រូវតែព្យាយាមកែវាឲ្យមកជាស្រី ដូចដើមវិញទាល់តែបាន ។


ព្រឹកឡើង...
លោកគុណ! សូមជួយ ស្រោចទឹក ដកស្នេហ៍ និងដេញគ្រោះ ឲ្យកូនខ្ញុំ ករុណាផង ។
អើ! មិនអីទេញោម ។


ពីបីថ្ងៃក្រោយមក...
ភ័ក្រ! ជួយយកទឹកមក ទទួលអ៊ំប្រុស គាត់មកលេង ។
បាទម៉ែ!
បងបាក់! ខ្ញុំទាល់តម្រិះមែនទែនហើយ មិនដឹងកែកាភាព បានយ៉ាងម៉េចទេ ។ ទៅរកគ្រូស្នេហ៍ ក៏ដោះហើយ ទៅស្រោចទឹកក៏ស្រោចហើយទៀត ។ វានៅមិនព្រមធ្វើខ្លួនជាស្រីវិញសោះ ។ បងជួយគិតខ្ញុំផង!
មើលទៅមិនស្រួលទេណា៎! បើបែបនេះមានតែយកទៅមណ្ឌលកែប្រែទេ ក្រែងកែវាបាន ។


ហឺ! តើខ្ញុំគួរជឿម៉ែទៅ? ប៉ើប៉ុណ្ណឹយ ខ្លាចតែវាខូចអោគត ។
ហឺ! មិនដឹងត្រូវធ្វើម៉េចទេ ដូចម៉ែគ្រូប្រាប់អញអត់ទេ ។
មិនបានទេ! ត្រូវតែយកវាទៅ មណ្ឌលហើយ ក្រែងគេរកវាបាន ។ ទោះជាខ្លាំងបន្តិចមែន តែ ត្រូវតែសាកល្បង ។


លោកប៉ូលិស! ជួយខ្ញុំផង!
មានការអី ដែរហ្នឹង?
Post Police
POLICE
កូនស្រីខ្ញុំញៀនថ្នាំបែកកម្លួង ទៅ តែងខ្លួនជាប្រុស ។ លោកប៉ូលិស ជួយយកវាទៅកែប្រែផង ។


ភាព! ចេញមក នេះតើជកូន!
ហ្អាក! ម៉េច ចាប់ខ្ញុំចឹង?!
ខ្ញុំអត់មានធ្វើអីខុសទេ ម៉េចក៏ចាប់ខ្ញុំ? ម៉ែ! ជួយខ្ញុំផងម៉ែ!
ទៅតាមគេទៅកូន! ថែខ្លួនណាកូន!
ម៉ែស្រលាញ់កូន មិនចង់ឲ្យកូនទៅក្លាយ ជាស្រីមិនស្រី ប្រុសមិនប្រុស ចឹងទេ ។


ម៉ែ! កុំទុកខ្ញុំនៅទីនេះ!
ម៉ែមិនចោលទេកូន តែម៉ែអស់សង្ឃឹមហើយ ។ ខំកែខ្លួនមកជាមនុស្សល្អដូចតាលោកកូន ។